សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ

# កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន
# ក្របខណ្ឌកម្មវិធីសិក្សា





## បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន
## ឯកទេសបង្រៀនប្រវត្តិវិទ្យា



គម្រោងកែលម្អការអប់រំចំណេះទូទៅ
២០២៣

## អារម្ភកថា

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំ ឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន តាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃច័ន្ទ ១២កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ប៉ាល់ ដែល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអេ អង្គារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រឿង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សូត្រ** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោកបណ្ឌិត | **អ៊ុន លាង** | ព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ម៉ម សុជាតិ** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោក | **សុត វិសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោកបណ្ឌិត | **ទង់ សុធារ៉ា** | ប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោក | **ឈុប សុខា** | អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោក | **ថា លាងអាង** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **គួង គានី** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **នាក់ ពិសិដ្ឋ** | អ្នកសម្របសម្រួលការបណ្ដុះបណ្ដាល មហាវិទ្យាល័យអប់រំ |
| ១០. លោកស្រី | **តាំង ឡាំង** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **ឆ្លួយ លាងស្រួយ** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១២. លោក | **យ៉ន ហើស** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអេ អង្គារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រឿង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ង៉ោ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈូក ច័ន្ទឆាយា** | អនុប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សារ៉ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

## ៤. ការីកុំព្យូទ័រ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ារ៉ាឌី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **ឌន សំណាង** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

# «អនុវត្ត រៀនសូត្រ សម្របខ បង្រៀន និងអភិវឌ្ឍ ដើម្បីដោះស្រាយ ភាពក្រីក្រសិក្សារៀនសូត្រ ភាពក្រីក្រសង្គម និងភាពក្រីក្ររូបិយវត្ថុ»

## “Apply, Learn, Adapt, Teach, and Develop Addressing Learning Poverty, Social Poverty, and Monetary Poverty”

# មាតិកា


**១. សេចក្តីផ្តើម** ........ 1

១.១ សាវតារ ........ 1

១.២ ព័ត៌មានសង្ខេប ........ 2

១.៣ គោលបំណង ........ 3

១.៤ ឈ្មោះកម្មវិធី និងសញ្ញាបត្រ ........ 3

**២. លទ្ធផលសិក្សារំពឹងទុក** ........ 3

**៣. អាជីពរំពឹងទុក** ........ 5

**៤. លក្ខខណ្ឌតម្រូវសម្រាប់បញ្ចប់ការសិក្សា និងច្រកចេញដើម្បីទទួលគុណវុឌ្ឍិ** ........ 6

**៥. ភាពបច់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា** ........ 6

៥.១ លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា ........ 7

**៦. ដំណើរការអនុវត្តកម្មវិធីសិក្សា** ........ 8

៦.១ ការអនុវត្តប្រព័ន្ធក្រេឌីត ........ 8

៦.២ រយៈពេលសិក្សា ........ 8

៦.៣ ការអនុវត្តកម្មវិធីសិក្សា ........ 8

៦.៤ ការវាយតម្លៃលើការសិក្សា ........ 9

៦.៤.១ គោលការណ៍វាយតម្លៃ ........ 9

៦.៤.២ ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់ ........ 9

៦.៥ គោលការណ៍ប្រតិបត្តិ ........ 10

៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា ........ 10

៦.៥.២ ការក្លែងបន្លំឯកសារ ........ 10

៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ ........ 11

# ១. សេចក្តីផ្តើម

ការសិក្សានៅគ្រប់កម្មវិធីរបស់មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចាំបាច់ត្រូវផ្តោតលើលទ្ធផល ស្របតាមយន្តការរបស់ ក្រសួងអប់រំ យុវជន និងកីឡា ដែលតម្រូវឱ្យគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងមន្ត្រីអប់រំ ត្រូវអនុវត្តភារកិច្ចប្រកបដោយ គណនេយ្យភាព និងតម្លាភាព ដើម្បីឱ្យលទ្ធផលការងារប្រសើរជាងមុន។ ស្របតាមសម័យកាលឌីជីថល និន្នាការអប់រំនិងមធ្យោបាយបំពេញការងារក៏មានការវិវត្តដែរ ដើម្បីធានាបានគុណភាពអប់រំសម្រាប់អ្នកទទួលសេវាអប់រំ។ ជាទិសដៅ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញសម្លឹងទៅរកគុណភាពអប់រំដែលឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ និងការអប់រំសតវត្សទី២១ ឆ្ពោះទៅរកការចូលរួមចំណែកបំពេញការងារស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលកម្ពុជានៅ មានចក្ខុវិស័យក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ដើម្បីឱ្យស្របទៅនឹងគោលដៅ និងមហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់ជាច្រើន ដែលក្នុងនោះក៏បានលើកឡើងពីការបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ដោយចាត់ទុកថា ទាំងគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនគឺជាកត្តាគន្លឹះ ក្នុងការជួយជំរុញសេដ្ឋកិច្ច និងសង្គមឌីជីថល ស្របតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ របស់រាជរដ្ឋាភិបាល។

ដើម្បីចូលរួមអភិវឌ្ឍធនធានមនុស្សស្របតាមទិសដៅខាងលើ កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រអប់រំប្រវត្តិវិទ្យានេះ ត្រូវបានតាក់តែងឡើងដោយផ្តើមចេញពីស្ថានភាពអប់រំកម្ពុជានាពេលបច្ចុប្បន្ន និងស្ថានភាពរបស់អ្នកសិក្សា ដោយជំរុញឱ្យអ្នកសិក្សាហ្វឹកហាត់ជាប្រចាំឱ្យមានសមត្ថភាពពេញលេញសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។ អ្នកសិក្សាគប្បីចាប់ផ្តើមដោយឈ្វេងយល់ចំណុចមួយចំនួន៖ តើការសិក្សារបស់សិស្សបង្ហាញលទ្ធផលយ៉ាងដូចម្តេច? តើលទ្ធផលនេះមានន័យយ៉ាងណា? តើខ្លួនខ្ញុំអាចធ្វើកិច្ចការអ្វីខ្លះបាន ដើម្បីកែប្រែលទ្ធផលនោះឱ្យកាន់តែប្រសើរ? តើខ្ញុំត្រូវរៀនអ្វីខ្លះ និងធ្វើអ្វីខ្លះ?

តាមរយៈរបាយការណ៍សន្និបាតអប់រំក្នុងរយៈពេល១០ឆ្នាំនេះ ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញនូវឧបសគ្គមួយចំនួនដែលធ្វើឱ្យអត្រាសិស្សបោះបង់ការសិក្សាខ្ពស់ អត្រាសិស្សដែលបន្តការសិក្សានៅមធ្យមសិក្សា និងឧត្តមសិក្សាទាប និងឧបសគ្គក្នុងការបណ្តុះបណ្តាលសិស្ស/និស្សិតឱ្យមានគុណភាពឆ្លើយតបទៅតាមតម្រូវការទីផ្សារ។ ក្នុងនាមជាគ្រឹះស្ថានបណ្តុះបណ្តាលមួយ សាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្តល់សេវាអប់រំដោយផ្តោតលើការចូលរួមចំណែកដោះស្រាយឧបសគ្គ និងបញ្ហាប្រឈមក្នុងវិស័យអប់រំដើម្បីលើកកម្ពស់សេវាអប់រំប្រកបដោយប្រសិទ្ធភាព។

## ១.១ សាវតារ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋដែលមានវ័យចំណាស់ជាងគេ ធំជាងគេ និងឈានមុខជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវបានបង្កើតឡើងតាមព្រះរាជក្រមលេខ ៣៦៧-ន.ស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦០។ ក្នុងប្រវត្តិសាស្ត្រកសាងធនធានមនុស្ស និងលើកកម្ពស់គុណភាពអប់រំក្នុងប្រទេសកន្លងមក តាមរយៈការបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និង

បណ្ឌិត សាកលវិទ្យាល័យរដ្ឋដ៏មានបទពិសោធន៍មួយនេះ ក៏ធ្លាប់ធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនផងដែរ។ ជាទឡ្ហីករណ៍ ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ សាកលវិទ្យា-ល័យភូមិន្ទភ្នំពេញ ដែលកាលនោះ តាមរយៈសាលាគរុវិជ្ជាជាន់ខ្ពស់(École Normale Supérieure) គឺជាកន្លែងសម្រាប់ធ្វើការបណ្តុះបណ្តាលគរុសិស្ស និងអ្នកសិក្សា ដែលនឹងត្រូវទៅបំពេញការងារជាគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សានានាក្នុងទូទាំងប្រទេសកម្ពុជា។

នៅឆ្នាំ២០១៧ សាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានជ្រើសរើសដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យអនុវត្តការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រអប់រំក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀននៃគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា។ គិតមកដល់ឆ្នាំ ២០២២ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រអប់រំឯកទេសចំនួន ៦ រួមមាន អក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា បានបីជំនាន់រួចមកហើយដល់អ្នកសិក្សាដែលជាគ្រូបង្រៀនចំនួន ២,១៦៤នាក់ និងឯកទេសគ្រប់គ្រងសាលារៀនបានពីរជំនាន់ដល់អ្នកសិក្សាដែលជាគណៈគ្រប់គ្រងសាលារៀននិងមន្ត្រីអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន ៤៣៦នាក់។

ជាលទ្ធផល និងផលជះនៃការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ អ្នកសិក្សាបានផ្លាស់ប្តូរឥរិយាបថខ្លួនក្នុងការបំពេញការងារគ្រប់គ្រង និងបង្រៀនដែលនាំឱ្យមានការប្រែប្រួលជាវិជ្ជមាននៅសាលារៀន។ គណៈគ្រប់គ្រងសាលារៀន បានរកឃើញមធ្យោបាយធ្វើការជាមួយគ្រូបង្រៀនដើម្បីធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើង អត្រាបោះបង់ការសិក្សាធ្លាក់ចុះ ទាំងការចូលរួមសហការរបស់អាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋានកើនឡើង។ ទាំងនេះជាសមិទ្ធកម្មនៃការកសាងបទពិសោធន៍ ក្នុងការផ្តល់សេវាបណ្តុះបណ្តាលផ្តោតលើលទ្ធផល។

ការរៀបចំកម្មវិធីសិក្សា និងទម្រង់នៃការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនគឺផ្អែកផ្អែកលើភស្តុតាងសមិទ្ធកម្មនៃការបណ្តុះបណ្តាលដែលនាំឱ្យផលសម្រេច ការឆ្លុះបញ្ចាំង ការស្រាវជ្រាវ និងការទទួលធាតុចូលពីអ្នកសិក្សាដែលបានអនុវត្តផ្ទាល់ និងពីភាគីពាក់ព័ន្ធ។ ទោះជាយ៉ាងនេះក្តី សាកលវិទ្យាល័យភូមិន្ទភ្នំពេញបន្តរក្សាការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា និងទម្រង់នៃការបណ្តុះបណ្តាល ដើម្បីធានាដល់ការអភិវឌ្ឍសមត្ថភាពរបស់អ្នកសិក្សាឱ្យមានលក្ខណៈឆ្លើយតបនឹងស្ថានភាពអប់រំនិងតម្រូវការសង្គមជាតិ។

## ១.២ ព័ត៌មានសង្ខេប

| កម្មវិធីសិក្សា | |
|---|---|
| ក្របខណ្ឌគុណវុឌ្ឍិជាតិ | កម្រិតទី៦ នៃក្របខណ្ឌគុណវុឌ្ឍិជាតិ |
| មហាវិទ្យាល័យ | អប់រំ |
| កម្មវិធី | កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន |
| កម្រិត និងឯកទេស | បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន, ឯកទេសបង្រៀនប្រវត្តិវិទ្យា |
| ចំនួនក្រេឌីត | ៦៣ |
| កាលបរិច្ឆេទ | ៣១ កក្កដា ២០២៣ |

### ១.៣ គោលបំណង

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន ដែលមាន ៦៣ ក្រេឌីតមានគោលបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរអប់រំដែលឆ្ពោះទៅរកទីប្រឹក្សាគរុកោសល្យបែបសតវត្សទី២១ សម្រាប់សាលារៀននៅមធ្យមសិក្សាទៅតាម ឯកទេស និងមុខវិជ្ជាស្នូលទាំង៦ រួមមាន អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និង ជីវវិទ្យា។ ការសិក្សាអាចជួយដល់អ្នកសិក្សាឱ្យមានមូលដ្ឋានគ្រឹះសម្រាប់បន្តអភិវឌ្ឍវិជ្ជាជីវៈខ្លួនឈានដល់អ្នកមានវិជ្ជាជីវៈដំបូង។

កម្មវិធីនេះសំដៅឆ្ពោះទៅការលើកកម្ពស់ការអប់រំ និងការសិក្សារៀនសូត្ររបស់សិស្សប្រកបដោយគុណភាពតាមតម្រូវការនិងការវិវត្តរបស់សង្គមជាតិ និងសកលលោក។ កម្មវិធីនឹងជំរុញទឹកចិត្តដល់អ្នកសិក្សាឱ្យបន្តការអនុវត្តការស្រាវជ្រាវ និងការរៀនសូត្រពេញមួយជីវិត ដើម្បីឆ្លើយតបនឹងតម្រូវការមូលធនមនុស្សដែលមានសមត្ថភាពទាំងផ្នែកឥរិយាបថ ផ្នែកចំណេះដឹងទូទៅ ផ្នែកការគិត និងផ្នែកចំណេះដឹងជំនាញក្នុងការបំពេញការងារ និងជីវភាពរស់នៅប្រចាំថ្ងៃ។

កម្មវិធីនេះនឹងផលិតមូលធនមនុស្សកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រអប់រំដែលអាច (១) មានមូលដ្ឋានគ្រឹះវិជ្ជាសម្បទា និងបំណិនសម្បទារឹងមាំសម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព (២) យល់ដឹងលើ និងអនុវត្តការស្រាវជ្រាវអប់រំ ដើម្បីបង្កើនសមត្ថភាពជំនាញ និងបទពិសោធបន្ថែមលើជំនាញវិជ្ជាជីវៈបង្រៀនរបស់ខ្លួន (៣) យកចំណេះដឹងសកលលោកមកបន្សីនឹងបរិបទមូលដ្ឋាន និងយកកម្មវិធីកំណែទម្រង់ថ្នាក់ជាតិមកអនុវត្តជាក់ស្តែងនៅសាលារៀន (៤) បង្កើតភាពជាម្ចាស់របស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននិងកសាងទំនុកចិត្តដល់សហគមន៍តាមតួនាទីរបស់ខ្លួន (៥) កសាងឥរិយាបថវិជ្ជមាន និងវប្បធម៌អភិវឌ្ឍវិជ្ជាជីវៈពេញមួយជីវិត និងបណ្តុះគុណធម៌ និងមនសិការ ក្នុងកាបំពេញកិច្ចការបង្រៀនដែលមានលក្ខណៈឆ្លើយតបនិងទទួលផលសម្រេចស្តង់ដាសាលារៀនមានប្រសិទ្ធភាព ។

### ១.៤ ឈ្មោះកម្មវិធី និងសញ្ញាបត្រ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន៖

| កម្រិតសញ្ញាបត្រ | ឯកទេស |
|---|---|
| បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន | បង្រៀនប្រវត្តិវិទ្យា |

## ២. លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្ត ទំនាក់ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជាឯកទេសប្រវត្តិវិទ្យាប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*

*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសប្រវត្តិវិទ្យាកម្រិតបរិញ្ញាបត្រ**

- ❖ ទ្រឹស្តីប្រវត្តិសាស្ត្រ
- ❖ ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរេប្រវត្តិដល់អង្គរ
- ❖ ប្រវត្តិសាស្ត្រកម្ពុជាសម័យក្រោយអង្គរដល់សម័យទំនើប
- ❖ ប្រវត្តិសាស្ត្រពិភពលោកសម័យបុរាណ
- ❖ ប្រវត្តិសាស្ត្រពិភពលោកសម័យទំនើប
- ❖ ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង
- ❖ សន្និកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា
- ❖ ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា

**(២) ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំប្រវត្តិវិទ្យាកម្រិតមធ្យមសិក្សា**

- ❖ វិធីសាស្ត្របង្រៀន
- ❖ វិធីសាស្ត្រវាយតម្លៃ
- ❖ ការស្រាវជ្រាវប្រតិបត្តិ
- ❖ ប្រឹក្សាគរុកោសល្យ
- ❖ បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង**

- ❖ អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ❖ ការអនុវត្តកម្មវិធីស្វ័យសិក្សាប្រវត្តិវិទ្យា ពីថ្នាក់ទី៧-ទី១២

❖ របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនប្រវត្តិវិទ្យាប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនប្រវត្តិវិទ្យា និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្តាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome ( PLO ) លទ្ធផលសិក្សាកម្មវិធីអប់រំ

## ៣. អាជីពរំពឹងទុក

ឱកាសការងារសម្រាប់អ្នកដែលបញ្ចប់ការសិក្សាដោយជោគជ័យពីកម្មវិធីបរិញ្ញបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះរួមមាន៖

- ❖ គ្រូបង្រៀនប្រវត្តិវិទ្យា
- ❖ អ្នកអភិវឌ្ឍកម្មវិធីសិក្សាប្រវត្តិវិទ្យា
- ❖ អ្នករៀបចំសម្ភារៈសិក្សាប្រវត្តិវិទ្យា
- ❖ អ្នកវាយតម្លៃការសិក្សាប្រវត្តិវិទ្យា
- ❖ ទីប្រឹក្សាគរុកោសល្យសម្រាប់គ្រូបង្រៀនប្រវត្តិវិទ្យា

❖ អ្នកអប់រំសែហគ្រិនភាព

## ៤. លក្ខខណ្ឌតម្រូវសម្រាប់បញ្ចប់ការសិក្សា និងច្រកចេញដើម្បីទទួលគុណវុឌ្ឍិ

ក្រោយពីបំពេញគ្រប់លក្ខខណ្ឌក្នុងការបញ្ចប់ការសិក្សាដោយជោគជ័យ អ្នកសិក្សានឹងទទួលបានសញ្ញាបត្រ កម្រិតបរិញ្ញាបត្រតាមឯកទេស ដែលអ្នកសិក្សាបានជ្រើសរើសដែលចេញដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

ដើម្បីបញ្ចប់ការសិក្សាដោយជោគជ័យ អ្នកសិក្សាត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បំពេញការសិក្សាមុខវិជ្ជាឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) ៣៦ ក្រេឌីត
- បំពេញមុខវិជ្ជាចំណេះដឹងគរុកោសល្យ វិធីសាស្រ្តបង្រៀន និងការអប់រំមធ្យមសិក្សា (២០%) ១២ (+៣) ក្រេឌីត
- ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) ១២ ក្រេឌីត

## ៥. កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្តោតលើបណ្តុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្រ្តបង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្តងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធអនុវត្តជាក់ស្តែងកន្លងមក ។

| បណ្តុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្រ្តបង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យវិធីសាស្រ្តបង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំ ចំនួន ៣ក្រេឌីត*

## ៥.១ លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្ដុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ទ្រឹស្ដីប្រវត្តិសាស្ត្រ | ៣ |
| | ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរេប្រវត្តិដល់អង្គរ | ៣ |
| | ប្រវត្តិសាស្ត្រកម្ពុជាសម័យក្រោយអង្គរដល់សម័យទំនើប | ៣ |
| | ប្រវត្តិសាស្ត្រពិភពលោកសម័យបុរាណ | ៣ |
| | ប្រវត្តិសាស្ត្រពិភពលោកសម័យទំនើប | ៣ |
| | អនុវត្តសន្លឹកកិច្ចការប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត១(ចងចាំ) | ៣ |
| | អនុវត្តសន្លឹកកិច្ចការប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |
| | សន្លឹកកិច្ចការប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្លឹកកិច្ចការប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |
| | សរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ * | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្ដែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្ដីពីការអនុវត្តស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| **សរុប** | | **៦៣** |

## ៦. ដំណើរការអនុវត្តកម្មវិធីសិក្សា

ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រនេះ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ប្រព័ន្ធក្រេឌីត និងគោលការណ៍ច្បាប់របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលអនុលោមតាមបទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តកម្មវិធីសិក្សាអាចមានលក្ខណៈបត់បែនដោយឈរលើមូលដ្ឋាននៃការផ្តោតលើផលសម្រេចការសិក្សារបស់អ្នកសិក្សាជាចម្បង។

### ៦.១ ការអនុវត្តប្រព័ន្ធក្រេឌីត

ការសិក្សាកម្រិតបរិញ្ញាបត្រអប់រំនេះមាន ៦៣ ក្រេឌីត។ យោងសេចក្តីសម្រេចលេខ ០៤/០៤ គ.ទ.ក.ស.ស.រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរការសិក្សា ការសិក្សា ១ ក្រេឌីតស្មើនឹង ៤៥ ម៉ោងនៃការសិក្សានៅក្នុងថ្នាក់ និងនៅក្រៅថ្នាក់។ ចំនួនម៉ោងសិក្សាអាចប្រែប្រួលទៅតាមនៃមុខវិជ្ជាសិក្សា ដូចបង្ហាញខាងក្រោម៖

- ❖ ការឧទ្ទេសៈ ១ ក្រេឌីតសម្រាប់ការឧទ្ទេសមាន ១៥ម៉ោងសិក្សាក្នុងថ្នាក់រៀននិង៣០ម៉ោងសិក្សាក្រៅថ្នាក់
- ❖ ការសិក្សាដោយពិសោធន៍/សិក្ខាសាលាៈ ១ ក្រេឌីត សមមូលនឹងការធ្វើពិសោធន៍ ៣០ម៉ោងនៅក្នុងមន្ទីរពិសោធន៍ ឬការបណ្តុះបណ្តាល ៣០ ម៉ោងតាមរយៈសិក្ខាសាលា និង១៥ម៉ោងនៃការសិក្សាក្រោមន្ទីរពិសោធន៍ ឬចូលរួមសិក្ខាសាលា
- ❖ ការធ្វើកម្មសិក្សាៈ ១ ក្រេឌីត មាន ៤៥ម៉ោងនៃការបណ្តុះបណ្តាលដែលបានធ្វើឡើងនៅក្នុងកសិដ្ឋាន/កន្លែងអនុវត្តការងារ និងនៅទីកន្លែងដែលពាក់ព័ន្ធផ្សេងទៀត។

ដោយអនុវត្តតាមប្រព័ន្ធក្រេឌីត អ្នកសិក្សាអាចជ្រើសរើសមុខវិជ្ជាសិក្សាតាមពេលវេលាជាក់ស្តែងក្នុងរយៈពេលកំណត់នៃកម្មវិធីអប់រំ។

### ៦.២ រយៈពេលសិក្សា

កម្មវិធីអប់រំសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះអាចមានរយៈពេលសិក្សារហូតដល់ ២៤ ខែ ឬ២ឆ្នាំសិក្សា។ អ្នកសិក្សាអាចបញ្ចប់ការសិក្សាយូរឬឆាប់អាស្រ័យលើការខិតខំបំពេញការសិក្សាតាមចំនួនក្រេឌីតដែលបានកំណត់។

### ៦.៣ ការអនុវត្តកម្មវិធីសិក្សា

ដំណើរការសិក្សាអាចធ្វើឡើងនៅក្នុងថ្នាក់ផ្ទាល់ ឬតាមរយៈការសិក្សាពីចម្ងាយឬអនឡាញន៍អាស្រ័យទៅតាមភាពជាក់ស្តែង។ ក្នុងការសិក្សា អ្នកសិក្សាត្រូវបំពេញឱ្យគ្រប់យ៉ាងតិច ៦០ ក្រេឌីតសម្រាប់កម្មវិធីទាំងមូល ហើយអាចបំពេញ ១៥ ក្រេឌីតជាមធ្យមសម្រាប់ឆមាសនីមួយៗ។ កាលវិភាគសិក្សាមានលក្ខណៈបត់បែននឹងរៀបចំតាមតម្រូវការជាក់ស្តែង។

ការអនុវត្តកម្មវិធីសិក្សាមានសកម្មភាពដូចខាងក្រោមសម្រាប់សម្របសម្រួលជូនអ្នកសិក្សា៖

- ❖ ការតម្រង់ទិសការសិក្សា និងកិច្ចការសម្រាប់អនុវត្តន៍
- ❖ ការសិក្សាមុខវិជ្ជាសិក្សាដែលមានទ្រឹស្តីភ្ជាប់នឹងការអនុវត្ត
- ❖ ការពិនិត្យតាមដានដំណើរសិក្សាមុខវិជ្ជាសិក្សា

- ការប្រឹក្សាយោបល់សម្រាប់ជួយដល់ដំណើរការសិក្សា
- ការសម្របសម្រួលដល់ការហាត់ការ/កម្មសិក្សាគរុកោលស្យ
- ការណែនាំអំពីឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

## ៦.៤ ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ

២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

### ៦.៤.២ ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average–GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point–P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value–C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីជានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹងវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែងដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មហាវិទ្យាល័យអប់រំផ្តល់ការបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់បណ្ឌិតដូចខាងក្រោម៖

- វិញ្ញាបនបត្រអប់រំកុមារតូច
- វិញ្ញាបនបត្រអប់រំបឋមសិក្សា

- បរិញ្ញាបត្រអប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រអប់រំ ឯកទេសអប់រំពេញមួយជីវិត
- បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសកម្មវិធីសិក្សានិងការបង្រៀនកម្រិតកុមារតូច

- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអប់រំពេញមួយជីវិត

- បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បណ្ឌិតអប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍការអប់រំ
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍធនធានមនុស្ស និងអប់រំពេញមួយជីវិត

**មហាវិទ្យាល័យអប់រំក៏មានផ្តល់សេវាប្រឹក្សាយោបល់ និងស្រាវជ្រាវអប់រំផងដែរ។**

សម្រាប់ព័ត៌មានបន្ថែម សូមស្កេនខាងក្រោម

www.facebook.com/rupp.edu.kh

www.rupp.edu.kh/fed/

Facebook Page
Faculty of Education